## ការជូនដំណឹងសំខាន់សម្រាប់គ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់

# អត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូន (គ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់)

សូមធ្វើការណែនាំ **អត្ថប្រយោជន៍ពិសេសថ្មី** សម្រាប់គ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់ដែលមានកូន!

## 1. បុគ្គលដែលមានសិទ្ធិទទួលបាន

- បុគ្គលដែលស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទទាំង 3 ខាងក្រោម
  (1) **បុគ្គលដែលបានទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូននៅខែមីនា ឆ្នាំ2023**
  (2) **បុគ្គលដែលមិនបានទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូននៅខែមីនា ឆ្នាំ2023** ដោយសារតែ**ទទួលបានប្រាក់សោធននិវត្តន៍សាធារណៈ ។ល។**
  (“ប្រាក់សោធននិវត្តន៍សាធារណៈ ។ល។” រួមបញ្ចូលប្រាក់សោធននិវត្តន៍សម្រាប់គ្រួសារដែលនៅរស់ ប្រាក់សោធននិវត្តន៍ពិការភាព ប្រាក់សោធននិវត្តន៍ចាស់ជរា ប្រាក់សំណងគ្រោះថ្នាក់ខាងឧស្សាហកម្ម ប្រាក់សំណងសម្រាប់គ្រួសារដែលបាត់បង់មនុស្សជាទីស្រឡាញ់ ។ល។)
  (3) **បុគ្គលដែលមានកម្រិតប្រាក់ចំណូលដូចគ្នានឹងអ្នកដែលទទួលបានប្រាក់ឧបត្ថម្ភចិញ្ចឹមកូន**ដែលហិរញ្ញវត្ថុគ្រួសាររបស់ខ្លួនត្រូវរងផលប៉ះពាល់ដោយកំណើនភ្លាមៗលើតម្លៃចំណីអាហារនិងទំនិញដទៃផ្សេងទៀត

* បុគ្គលដែលបានទទួលរួចហើយនូវអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូនដែលមិនមែនជាគ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់ ពុំមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះឡើយ ដោយមិនគិតពីប្រភេទទី (2) ឬ (3) ខាងលើឡើយ។

## 2. ចំនួនប្រាក់អត្ថប្រយោជន៍

**50,000 យ៉េន** ក្នុងកូនមួយនាក់

- **នីតិវិធីសម្រាប់ការទទួលបានអត្ថប្រយោជន៍នេះ មានចែងនៅលើទំព័រម្ខាងទៀតនៃទំព័រនេះ។ សូមធ្វើការត្រួតពិនិត្យព័ត៌មានដែលផ្ដល់ជូន**

* ប្រសិនបើមានសំណួរណាមួយ សូមទូរស័ព្ទទៅលេខខាងក្រោម។

- មជ្ឈមណ្ឌលសេវាអតិថិជនរបស់ទីភ្នាក់ងារកុមារនិងគ្រួសារ

**0120-400-903** (ម៉ោង៖ 9:00 ព្រឹក – 6:00 ល្ងាច ថ្ងៃធ្វើការ)

- **ទាក់ទងទៅកាន់សាលាក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នកដែលធ្វើការពាក់ព័ន្ធនឹងអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារដែលមានកូន (គ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់) សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យស្នើសុំ។**

## 3. នីតិវិធីសម្រាប់ការទទួលបានអត្ថប្រយោជន៍

### ■ បុគ្គលដែលបានទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូននៅខែមីនា ឆ្នាំ2023 (បុគ្គលស្ថិតក្នុងប្រភេទ (1) នៅផ្នែកខាងខ្នង)

▶ **ពុំចាំបាច់មានពាក្យស្នើសុំ** ដើម្បីទទួលបានអត្ថប្រយោជន៍ឡើយ។

▶ អត្ថប្រយោជន៍នឹងត្រូវផ្ទេរទៅកាន់គណនីធនាគារដែលបានកំណត់សម្រាប់ប្រាក់ឧបបត្ថម្ភចិញ្ចឹមកូននៅក្នុង **ខែឧសភា**។

[ចំណាំ]
* បុគ្គលដែលពុំមានបំណងចង់ទទួលអត្ថប្រយោជន៍ ត្រូវធ្វើការជូនដំណឹងអំពីការបដិសេធរបស់ខ្លួន។
* ប្រសិនបើអាចមានលទ្ធភាពដែលការទូទាត់ប្រាក់អត្ថប្រយោជន៍ ត្រូវបានធ្វើឡើងពុំត្រឹមត្រូវ ដូចជា ដោយសារគណនីដែលបានកំណត់សម្រាប់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូន ត្រូវបានបិទជាដើម ដូច្នេះ អ្នកត្រូវប្រាកដថាបានធ្វើការផ្លាស់ប្តូរគណនីដែលបានកំណត់នោះ ឬចាត់វិធានការបង្ការជាមុនទៅតាមការចាំបាច់។

### ■ បុគ្គលផ្សេងទៀតក្រៅពីបុគ្គលខាងលើ (បុគ្គលដែលស្ថិតក្នុង ប្រភេទទី (2) ឬទី (3) ស្ថិតក្រោមផ្នែក 1 នៅផ្នែកខាងខ្នង)

▶ **ចាំបាច់ត្រូវមានពាក្យស្នើសុំ** ដើម្បីទទួលបានអត្ថប្រយោជន៍។

▶ សូមបំពេញទម្រង់បែបបទពាក្យស្នើសុំនេះ (រួមបញ្ចូលទាំងព័ត៌មានគណនីធនាគាររបស់អ្នកផង) និងប្រគល់ទម្រង់បែបបទនេះរួមគ្នាជាមួយនឹងឯកសារដែលចាំបាច់ **ដោយផ្ទាល់ទៅកាន់ការិយាល័យក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នក** ឬ **តាមសំបុត្រប្រៃសណីយ៍**។

▶ពាក្យស្នើសុំនឹងត្រូវធ្វើការផ្ទៀងផ្ទាត់ ហើយអត្ថប្រយោជន៍នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីដែលបានបញ្ជាក់**ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន** សម្រាប់អ្នកដាក់ពាក្យស្នើសុំដែលបំពេញតាមលក្ខខណ្ឌដែលបានតម្រូវ។




**សូមមានការប្រុងប្រយ័ត្នចំពោះ ករណីឆបោកដែលអាចកើតមានចំពោះការផ្ទេរប្រាក់តាមធនាគារ និងករណីឆបោកព័ត៌មានផ្ទាល់ខ្លួនពាក់ព័ន្ធនឹងអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូន។**

ទាក់ទងទៅកាន់សាលាក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នក ប៉ុស្តិ៍នគរបាលដែលនៅជិតបំផុត ឬខ្សែទូរស័ព្ទប្រឹក្សាយោបល់ជាមួយប៉ូលិសដែលបានកំណត់ (#9110) ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទដែលមានការសង្ស័យ ឬការឆ្លើយតបតាមសំបុត្រប្រៃសណីយ៍ទៅកាន់ផ្ទះ ឬកន្លែងធ្វើការរបស់អ្នកពីនរណាម្នាក់ដែលបានអះអាងថាជាបុគ្គលិករដ្ឋបាលស្រុកឬក្រុង ឬថាជាតំណាងទីភ្នាក់ងារកុមារនិងគ្រួសារ។